**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាអគ្គសញ្ញាអាពាហ៍ពិពាហ៍នៅប៉ោយប៉ែត**
**ប៉ោយប៉ែត ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩**
**គ្រួសារដ៏វិសុទ្ធជាគំរូដ៏ពិសេស**

**អត្ថបទទី១៖ កំណើតពិភពលោក ២,១៨-២៤**

ហេតុនេះ បុរសចាកចេញពីឪពុកម្ដាយទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ។ កណ ២,២៤

**អត្ថបទទី២៖ ១ករ ១៣,១-៧**

ទោះបីខ្ញុំយកទ្រព្យសម្បត្តិរបស់ខ្ញុំទាំងប៉ុន្មានទៅចែកទានក្ដី ទោះបីខ្ញុំសុខចិត្តឲ្យគេយករូបកាយខ្ញុំទៅដុតទាំងរស់ក្ដី តែបើសិនជាខ្ញុំគ្មានសេចក្ដីស្រឡាញ់ទេ នោះ ក៏គ្មានប្រយោជន៍អ្វីដល់ខ្ញុំដែរ។ ១ករ ១៣,៣

**ដំណឹងល្អ៖ ម៉ាថាយ ១៩,១-៦**

គេមិនមែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែមួយវិញ។ ដូច្នេះ មនុស្សមិនត្រូវបំបាក់បំបែកគូស្រករ ដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ»។ មថ ១៩,៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះព្រះសហគមន៍រីកចម្រើនថែមទៀត ដោយសារទទួលគ្រួសារថ្មីមួយ គឺកាតារីណា និងយ៉ូហានបូស្កូ ដែលរៀបការនៅមុខព្រះជាម្ចាស់។ ថ្ងៃនេះ រួមជាមួយព្រះសហគមន៍យើងស្វាគមន៍គ្រួសារមួយ អត្ថបទថ្ងៃនេះមានសំណួរមួយប្លែកគឺ "**តើស្វាមីមានសិទ្ធិនឹងលែងភរិយាដោយសំអាងលើមូលហេតុអ្វីក៏ដោយបានឬទេ?**" ជាសំណួរដែលយើងមិនចង់សួរទេថ្ងៃនេះ។ ផ្ទុយទៅវិញយើងត្រូវការស្ដាប់ចម្លើយរបស់ព្រះយេស៊ូថា "**ដូច្នេះមនុស្សមិនត្រូវបំបាក់បំបែកគូស្រករដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ**" នេះជាចម្លើយរបស់ព្រះសហគមន៍នៅថ្ងៃនេះ។ ថ្ងៃនេះទាំងពីរនាក់សុខចិត្តរៀបការដោយសារស្គាល់គ្នា និងស្រឡាញ់គ្នាពីយូរឆ្នាំមកហើយ ថ្ងៃនេះយើងជាសាក្សីសម្រាប់ទាំងពីរនាក់ដែលធ្វើជាប្ដីប្រពន្ធ ដោយយើងដឹងថាថ្ងៃនេះគេរៀបការសម្រាប់អស់មួយជីវិត។

ធ្លាប់មានយាយម្នាក់ដែលបាននិយាយទៅកូនចៅរបស់គាត់ពេលរៀបការ "**កូនចៅអើយ ថ្ងៃនេះជាថ្ងៃអាពាហ៍ពិពាហ៍ដែលជាពេលវេលាមួយយ៉ាងពិសេស ដោយសារជាសញ្ញាបត្រដែលយើងទទួលដោយអត់បានរៀនអ្វីសោះ**"។ ពិតមែនថ្ងៃនេះ ទាំងពីរនាក់បានទទួលសញ្ញាបត្រមួយពិសេសពីព្រះជាម្ចាស់ ដោយកូនកម្លោះ យ៉ូហានបូស្កូ ហាន និងកូនក្រមុំ កាតារីណា ហ៊ួយ បានរៀបការនៅមុខព្រះជាម្ចាស់ក្នុងព្រះវិហារសន្តីម៉ារីម៉ាដាឡាប៉ោយប៉ែត នៅថ្ងៃទី១៨ ខែមករា ឆ្នាំ

២០១៩ ដោយមានខ្ញុំ លោកអភិបាល អូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ចុះហត្ថលេខាដោយនាមលោកអភិបាល គឺគេ មានលោកបូជាចារ្យទទួលខុសត្រូវ និងសាក្សីក៏ត្រូវចុះហត្ថលេខាដែរ។ ថ្ងៃនេះគេបានសញ្ញាបត្រមួយដែលអត់បានរៀន អត់បានប្រឡងអ្វីសោះ តែជាសញ្ញាបត្រដែលត្រូវការជាប់អស់មួយជីវិត។ ផ្ទុយពីលោកបូជាចារ្យ ដើម្បីបួសធ្វើជាបូជាចារ្យយ៉ាងតិចយើងត្រូវរៀន១០ឆ្នាំ។

ថ្ងៃនេះយើងចូលនៅក្នុងពេលវេលាមួយពិសេស ដោយដឹងថាយើងធ្លាក់នៅក្នុងរឿងស្នេហា ឥឡូវនេះយើងជាប់នៅក្នុងរឿងស្រឡាញ់និងយើងចូលនៅក្នុងជីវិតថ្មីមួយដែលចាប់ពីពេលនេះតទៅត្រូវតែពោរពេញដោយសេចក្តីសុខ។ យើងមានគំរូពិសេស សម្រាប់ទាំងពីរនាក់គឺសូមនឹកឃើញព្រះនាងម៉ារីនិងលោកយ៉ូសែប ដែលជាគ្រួសារដ៏វិសុទ្ធនិងជាគំរូដ៏ពិសេសគឺៈ

**ទីមួយ** យើងនឹកឃើញពេលព្រះនាងម៉ារីនិងលោកយ៉ូសែបធ្វើដំណើរទៅបេថ្លេហិម ដល់ពេលវេលាសម្រាលកូនឥតមានកន្លែង។ ប៉ុន្តែលោកយ៉ូសែប បានយកចិត្តទុកដាក់ទៅរកកន្លែងមួយទៅកន្លែងមួយរហូតរកឃើញក្រោលគោមួយ ធ្វើឲ្យគាត់ទាំងពីរនាក់សប្បាយចិត្តណាស់ដោយសារមានកន្លែងដើម្បីសម្រាលកូនហើយ។ ប៉ុន្តែសេចក្តីសុខសាន្តដែលគាត់បានទទួល គឺលោកយ៉ូសែបបានថែរក្សាព្រះនាងម៉ារី បានយកចិត្តទុកដាក់ជាមួយភរិយាគាត់ ធ្វើឲ្យប្រពន្ធគាត់បានរស់នៅក្នុងសេចក្តីសុខជាមួយគាត់។ ដើម្បីឲ្យយើងជាប់ កុំឲ្យសញ្ញាបត្ររបស់យើងនៅតែមួយរយៈប៉ុន្តែជាប់មួយជីវិត គឺត្រូវថែរក្សាគ្នាទៅវិញទៅមកនៅក្នុងសេចក្តីស្រឡាញ់ជាសេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់។

**ទីពីរ** យើងនឹកឃើញព្រះយេស៊ូ ដែលជាកូនជាផ្លែនៃសេចក្តីស្រឡាញ់រវាងប្តីនឹងប្រពន្ធគ្រួសារដ៏វិសុទ្ធលុះត្រាតែយើងទទួលស្វាគមន៍កូន។ ដូច្នេះយើងត្រូវតែអធិដ្ឋាន ដើម្បីឲ្យទាំងពីរនាក់ទទួលកូនបានច្រើន ដើម្បីឲ្យទទួលសេចក្តីសុខ។

**ទីបី** ព្រះនាងម៉ារីនិងលោកយ៉ូសែប បានស្វាគមន៍បងប្អូនអ្នកភូមិ ហោរាចារ្យ អ្នកគង្វាលមិនមែនជាគ្រួសារដែលចង្អៀតចង្អល់ដែលគិតតែប្តីប្រពន្ធកូន ប៉ុន្តែជាគ្រួសារដែលស្វាគមន៍ភ្ញៀវគឺទទួលស្វាគមន៍បងប្អូនទាំងអស់ដែលមកសួរសុខទុក្ខយើង។ គ្រួសារដែលយើងបង្កើតកុំឲ្យទៅជាគ្រួសារចង្អៀតចង្អល់ ផ្ទុយនឹងអ្វីដែលយើងឃើញសព្វថ្ងៃឪពុកម្តាយបានឲ្យកូនគេជាប់ជាមួយទូរសព្ទទំនើបតាំងពីតូចមកម្ល៉េះ។ កុំឲ្យយើងធ្វើជាគ្រួសារមួយដែលគ្មានសេចក្តីសុខ ដោយសារយើងឥតចេះបង្កើតទំនាក់ទំនងដ៏សុខសាន្តជាមួយអ្នកដទៃ។

**ទីបួន** នៅពេលសម្រាលកូនហើយ គ្រួសារដ៏វិសុទ្ធបានរត់គេចខ្លួនទៅប្រទេសអេហ្ស៊ីបដោយសារ ស្តេចហេរ៉ូដចង់សម្លាប់កូនង៉ែតដែលមានអាយុក្រោម២ឆ្នាំ។ ទាំងពីរនាក់គេតស៊ូណាស់ នេះសំខាន់ណាស់ដោយសារគ្រួសារដ៏សុខសាន្តជាគ្រួសារដែលចេះតស៊ូ។ ពេលយើង

ជាប្ដីប្រពន្ធយើងដឹងហើយថាបញ្ហាក៏មាន អំណរសប្បាយក៏មាន តែឲ្យយើងចេះតស៊ូដើម្បីស្វែងរកសេចក្ដីសុខដោយចាំនេះ "**អ្នកមានចិត្តស្រឡាញ់តែងតែ អត់ឱនឲ្យទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ទ្រាំទ្រទាំងអស់**"។ ឲ្យយើងចេះនិយាយគ្នា ដោយចេះប្រើពាក្យ បងស្រឡាញ់អូន អូនស្រឡាញ់បង ដូចកាលដែលយើងស្រឡាញ់គ្នាដំបូង។

**ទីប្រាំ** ក្រោយមកលោកយ៉ូសែប និងព្រះនាងម៉ារី បានថ្វាយកូនទៅវិសាលវិហារនៅទីក្រុងយេរ៉ូសាឡឹម ថ្វាយកូនទៅព្រះជាម្ចាស់ដើម្បីគោរពប្រពៃណីសាសនា។ ថ្ងៃនេះ យើងបានបង្កើតគ្រួសារកាតូលិកមួយ ត្រូវបង្រៀនឲ្យកូនចេះគូសសញ្ញាឈើឆ្កាង ចេះសូត្រធម៌ឱព្រះបិតា បពិត្រព្រះនាងម៉ារី ឪពុកម្ដាយជាគ្រូអប់រំជំនឿមុនគេបង្អស់ពីកូននៅតូចរហូតដល់កូនធំ ដើម្បីឲ្យយើងមានសេចក្ដីសុខដោយយើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។

ដូច្នេះគ្រួសារដ៏សុខសាន្ត គឺចេះគោរពគ្នាទៅវិញទៅមក បង្កើតទំនាក់ទំនងជាមួយគ្នាយ៉ាងល្អ បង្កើតកូនច្រើន ស្វាគមន៍បងប្អូនទាំងអស់ដោយមានចិត្តអាណិតមេត្តាជានិច្ច និងតស៊ូជានិច្ច និងនៅតែស្រឡាញ់គ្នាជារៀងរហូត។ អាម៉ែន៕